# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៥ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

### សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដី: អធិការដ្ឋាននគរបាលស្រុកកំពង់ចាមដែលមានទំហំដី៩០០.០៥ម៉ែត្រក្រឡា អតីតផ្ទះភ្ញៀវខេត្តកំពង់ចាមមានទំហំដី ៣៦.០០៦ ម៉ែត្រក្រឡា សាលាស្រុកស្ទឹងសែនខេត្តកំពង់ធំមានទំហំដី ៣.២១៤ ម៉ែត្រក្រឡា ទីតាំងកងកំលាំងនគរបាលអង្គភាពអន្តរាគមន៍ក្រសួងមហាផ្ទៃមានទំហំដី១០៤.៨៩០ ម៉ែត្រក្រឡា ទីតាំងមួយផ្នែកទំហំ ៦.០៤៨ ម៉ែត្រក្រឡានៃចំណតរថយន្តផ្សារវាលយន្តខេត្តស្វាយរៀង ទីតាំងដីមួយផ្នែករបស់អង្គភាពអន្តរាគមន៍ នៃមជ្ឈមណ្ឌលគ្រឿងចក្រធំៗ របស់ក្រសួងសាធារណការ និង

ដឹកជញ្ជូនមានទំហំដី ៦៧.០០០ ម៉ែត្រក្រឡា ទីតាំងអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាបមានទំហំដី៥.៤៨៤ម៉ែត្រក្រឡា ទីតាំងស្ថានីយ៍ពិសោធន៍ពូជនីជណាំទូលក្រសាំងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានទំហំដី ៩៩១.៤៧០.៧៩ ម៉ែត្រក្រឡា និង ទីតាំងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដែលមានទំហំដី ២.៣៦៧ ម៉ែត្រក្រឡា ។

**មាត្រា ២.-**

ការកត់ត្រាទ្រព្យសម្បត្តិថ្មីដែលទទួលបានពីការដោះដូរ ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សាលាខេត្តកំពង់ចាម សាលាខេត្តកំពង់ធំ និង មន្ទីរជំនាញពាក់ព័ន្ធ ស្របគោលការណ៍របស់រាជរដ្ឋាភិបាលស្តីពីការធ្វើឯកជនភាវូបនីយកម្ម ។

**មាត្រា ៣.-**

ការបំពេញបែបបទធ្វើកម្មសិទ្ធិរបស់ភាគីឯកជនលើទីតាំងរបស់រដ្ឋ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អាជ្ញាធរខេត្តកំពង់ចាម អាជ្ញាធរខេត្តកំពង់ធំ និង មន្ទីរជំនាញពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ